## តើអ្នកដឹងថា ក្រសួងសាធារណសុខភាព...

- ត្រួតពិនិត្យ និងឲ្យគុណភាពភោជនីយដ្ឋាន ទីផ្សារ និងឡានដឹកម្ហូប ដើម្បីការពារជំងឺជាប់ទាក់ទងនឹងម្ហូបអាហារ ឬទេ?
- សង្កេតមើលទឹកសមុទ្រ និងអាងហែលទឹក ដើម្បីឲ្យប្រាកដថាកន្លែងហែលទឹកមានសុវត្ថិភាព ឬទេ?
- ព្យាបាលអ្នកដែលមានកាមរោគ គឺរោគឆ្លងតាមការរួមដំណេក និងរោគ HIV/AIDS ឬទេ?
- ជួយអ្នកមូលដ្ឋានឲ្យប្រុងប្រយ័ត្ន សំរាប់អាសន្នបណ្តាលដោយសារធម្មជាតិ និងមនុស្ស និងគ្រោះអន្តរាយ ឬទេ?
- ត្រួតពិនិត្យ ហើយឲ្យអាជ្ញាបត្រទៅមន្ទីរពេទ្យ និងលំនៅថែរក្សាជនចាស់ជរា ឬទេ?
- ត្រួតត្រាសត្វ ពួកសត្វកកេរ និងសត្វល្អិតជាបុព្វហេតុដែលអាចនឹងបណ្តាលឲ្យមានជំងឺ ឬទេ?
- ធ្វើការសួរសុខទុក្ខដល់ផ្ទះ ដើម្បីសំរបសំរួលការថៃទាំស្ត្រីមានផ្ទៃពោះដែលស្ថិតក្នុងគ្រោះថ្នាក់ខ្លាំង ឬទេ?
- ផ្តល់សេវាការពិសោធន៍រោគ ដើម្បីសំគាល់ជំងឺ និងអ្វីៗដែលគ្រោះថ្នាក់ដល់សុខភាព ឬទេ?

## រក្សាការតាមដានជាមួយនឹងដំណឹងថ្មីៗ ចេញពីក្រសួងសាធារណសុខភាព

វ៉ិបសៃត៍ : www.publichealth.lacounty.gov

អង់គ្លេស : www.facebook.com/lapublichealth

www.twitter.com/lapublichealth

www.youtube.com/lapublichealth

ថតចំឡងលេខ QR នេះ ដើម្បីឲ្យបានជ្រាបថែមទៀតអំពី ក្រសួងសាធារណសុខភាព


គណៈនៃអ្នកមើលការខុសត្រូវ ខោនធី **Los Angeles**

Gloria Molina *មណ្ឌលទីមួយ*
Mark Ridley-Thomas *មណ្ឌលទីពីរ*
Zev Yaroslavsky *មណ្ឌលទីបី*
Don Knabe *មណ្ឌលទីបួន*
Michael D. Antonovich *មណ្ឌលទីប្រាំ*

ក្រសួងសាធារណសុខភាព ខោនធី **Los Angeles**

Jonathan E. Fielding, MD, MPH
*នាយក និងប្រមុខសុខភាព*



10/11 Khmer


# ក្រសួងសាធារណសុខភាព

នៃខោនធី Los Angeles



*បេសកកម្មរបស់ក្រសួងសាធារណសុខភាព នៃខោនធី Los Angeles គឺដើម្បីការពារសុខភាព ការពារជំងឺ និងផ្សព្វផ្សាយសុខភាព និងសុខុមាលភាពនៃប្រជាជនទាំងអស់ ក្នុងខោនធី Los Angeles*



## តើក្រសួងសាធារណសុខភាព ជួយសហគមន៍ដោយដូចម្តេច?

### ក្រសួងសាធារណសុខភាព បានផ្តោតចិត្តទៅលើរបៀបការពារ និងធ្វើការក្នុងវិស័យជាច្រើន ដើម្បីការពារ និងធ្វើឲ្យសុខភាពនៃសហគមន៍របស់យើង ល្អប្រសើរឡើង។

ទោះជាការត្រួតពិនិត្យភោជនីដ្ឋាន ឆ្នេរសមុទ្រ ឬលំនៅថែរក្សាជនចាស់ជរា; ព្យាបាលជំងឺឆ្លងរាលដាល នៅឯមណ្ឌលសាធារណសុខភាព; ការតបឆ្លើយចំពោះការបែកសាររោគឧបទ្រព ឬភាពអាសន្ន ដូចជារោគរាតត្បាត ឬការរំជួយធរណី; ការអប់រំសាធារណជន និងអ្នកដឹកនាំសហគមន៍ តាមរយៈព្រឹត្តិការណ៍ផ្សេងៗ និងការប្រជុំគ្នា; ធ្វើការស្ទង់មតិ ដើម្បីស្ទង់មើលសុខភាពរបស់ប្រជាជន; ឬការបង្កើតច្បាប់ដោយផ្តោតទៅលើការធ្វើឲ្យសុខភាពល្អប្រសើរប្រសើរ នោះការ ងាររបស់ក្រសួង អាចបានឃើញ និងបានដឹង នៅពាសពេញ ខោនធី Los Angeles ដែលមានផ្ទៃដីទំហំ 4,300 ម៉ៃការ៉េ។ ពីមួយថ្ងៃទៅមួយថ្ងៃ អ្នកធ្វើការស្ទើរតែ 4,000 នាក់ ដែលជាបុគ្គលិកនៃ 39 កម្មវិធី របស់ក្រសួង បានប្តេជ្ញាដើម្បីការពារសុខភាពរបស់អ្នកមូលដ្ឋាន ខោនធី LA និងធ្វើឲ្យសហគមន៍ល្អប្រសើរឡើង និង មានសុខភាពល្អប្រពៃឡើង ជាកន្លែងដ៏ល្អល្អះដើម្បីរស់នៅ។



## កម្មវិធី និងសេវា

មានកម្មវិធីច្រើនសន្ធឹកសន្ធាប់ ដែលអាចធ្វើឲ្យក្រសួងសាធារណសុខភាព ដើម្បីការពារ និងធ្វើឲ្យសុខភាពរបស់អ្នកមូលដ្ឋាននៃខោនធី LA ល្អប្រពៃ។

ជាលំដាប់ទៅនេះ គឺគ្រាន់តែជាកម្មវិធីបន្តិចបន្តួចរបស់ក្រសួង។

**សេវាសុខភាពរបស់កុមារ :** ការត្រួតពិនិត្យ និងការព្យាបាលក្មេងៗអាយុ 21 ឆ្នាំ និងក្មេងជាង។

**ជំងឺរ៉ាំរ៉ៃ :** យកចិត្តទុកដាក់ទៅលើការបន្ថយការកើតហេតុ តាមរយៈការផ្លាស់ប្តូរបរិស្ថាន និងលក្ខណៈជីវភាព។

**ការទប់ស្កាត់ និងបង្ការជំងឺឆ្លងរាលដាល :** ស្វះស្វែងបន្ថយកត្តាគ្រោះថ្នាក់ តាមរយៈការឃ្លាំមើលជំងឺ និងផ្សព្វផ្សាយឥរិយាបថសុខភាព។

**សេវាសុខភាពសហគមន៍ :** ផ្តល់ការពិនិត្យនៅវេជ្ជមន្ទីរ និងការចាត់ចែងករណីតាមរយៈមណ្ឌលសាធារណសុខភាព។

**ការប្រុងប្រៀបសំរាប់អាសន្ន និងការតបឆ្លើយ :** ប្រុងប្រៀបអ្នកមូលដ្ឋាន សំរាប់ការយាយីសុខភាពសាធារណៈ ដូចជាជំងឺឆ្លងរាលដាល និងភេរវកម្មបញ្ចេញអង្គធាតុពិសពុល។

**សុខភាពបរិស្ថាន :** ផ្សព្វផ្សាយគុណភាពនៃជីវិត ដោយត្រួតត្រាកត្តាបរិស្ថាន ដោយរួមមានការត្រួតពិនិត្យភោជនីយដ្ឋាន។

**ការប្រមាណសុខភាព និងវិជ្ជាខាងអាសន្នរោគ :** បង្កើតការស្ទង់មើល ដើម្បីប្រមូលទិន្នន័យ ស្តីពីលក្ខណៈសុខភាព និងឥរិយាបថ។

**ការត្រួតពិនិត្យមន្ទីរសុខភាព :** ទទួលខុសត្រូវសំរាប់ការចេញអាជ្ញាបត្រ និងការបញ្ជាក់ ស្ទើរតែ 2,000 មន្ទីរសុខភាព។

រោគ **HIV/AIDS :** ស្វះស្វែងដើម្បីការពារ នូវការឆ្លងរាលដាលនៃរោគ HIV/AIDS។

**ការចាក់ថ្នាំការពាររោគ :** ការពារសហគមន៍ ដោយចាក់ថ្នាំបង្ការរោគ ប្រឆាំងនឹងជំងឺដែលអាចការពារបាន។

**សុខភាពម្តាយ កុមារ និងតរុណវ័យ :** វាយដំឡៃ គ្រោងការ និងផ្តល់សេវាសំរាប់ក្រុមទាំងនេះ។

**ការស៊ើបអង្កេតសាធារណសុខភាព :** ការពារសុខភាពសាធារណជន តាមរយៈការប្រតិបត្តិច្បាប់សាធារណសុខភាព។

**មន្ទីរពិសោធន៍សាធារណសុខភាព :** ការពារសុខភាពសាធារណៈ តាមរយៈការពិសោធន៍ធ្វើតេស្ត។

**សុខភាពព្រឹទ្ធវ័យ :** ធ្វើឲ្យគុណភាពជីវិតរបស់មនុស្សវ័យចាស់ជរា និងគ្រួសាររបស់គេ ប្រសើរឡើង។

**កាមរោគ (ជំងឺឆ្លងតាមរយៈការរួមដំណេក) :** ធ្វើការដើម្បីការពារ និងទប់ស្កាត់កាមរោគ (STD) នៅពាសពេញទាំងខោនធី។

**វិធីការពារ និងទប់ស្កាត់ ការរំលោភសារធាតុញៀន :** ខិតខំប្រឹងប្រែងដើម្បីបន្ថយការរំលោភសារធាតុញៀន តាមរយៈកម្មវិធីយោងតាមភស្តុតាង និងច្បាប់គាំពារ។

**រោគរបេង :** ស្វះស្វែងដើម្បីការពារ នូវការចំឡងជំងឺ តាមរយៈការរកឃើញពីដំបូង នូវជំងឺដែលសកម្ម និងការព្យាបាលជំងឺដែលសំងំ។

**ពេទ្យសត្វត្រួតត្រាសាធារណសុខភាព និងជំងឺឆ្កែឆ្កួត :** ស៊ើបអង្កេតការបែកសាយនៃជំងឺសត្វ និងសត្វខាំឬទិច។

**សុខភាពរបស់ស្ត្រី :** ខិតខំប្រឹងប្រែងដើម្បីធ្វើឲ្យសុខភាពល្អប្រពៃ តាមរយៈយុទ្ធវិធីការរៀបចំគំរោងការ រួមមានទាំងលេខពិសេសសុខភាពរបស់ស្ត្រី។

## មណ្ឌលសាធារណសុខភាព

ក្រសួងសាធារណសុខភាព មានមណ្ឌលសុខភាព **14** កន្លែង ដែលផ្តល់សេវា ដោយឥតគិតថ្លៃ និងថោកថ្លៃ សំរាប់អស់អ្នកដែលគ្មានការធានារ៉ាប់រង ឬគ្មានអ្នកផ្តល់ការថែទាំសុខភាពទៀងទាត់។

*សេវាដែលផ្តល់ឲ្យ គឺការចាក់ថ្នាំការពាររោគ, ការត្រួតពិនិត្យរោគរបេង (TB) និងការព្យាបាល, និងការធ្វើតេស្តកាមរោគ (STD) និងការព្យាបាល។*

**A** មណ្ឌលសាធារណសុខភាព
**Antelope Valley**
335-B East Ave. K-6
Lancaster, CA 93535
(661) 723-4526

**B** មជ្ឈដ្ឋានមណ្ឌលសាធារណសុខភាព
**Central**
241 N. Figueroa St.
Los Angeles, CA 90012
(213) 240-8204

**C** មណ្ឌលសាធារណសុខភាព
**Curtis R. Tucker**
123 W. Manchester Blvd.
Inglewood, CA 90301
(310) 419-5325

**D** មណ្ឌលសាធារណសុខភាព
**Glendale**
501 N. Glendale Ave.
Glendale, CA 91206
(818) 500-5750
*បំរើតែការចាក់ថ្នាំការពាររោគ និងរោគរបេង; វេជ្ជមន្ទីររោគរបេងគឺតាមការណាត់ជួប*

**E** មណ្ឌលសាធារណសុខភាព
**Hollywood/Wilshire**
5205 Melrose Ave.
Los Angeles, CA 90038
(323) 769-7800

**F** មណ្ឌលសាធារណសុខភាព
**Monrovia**
330 W. Maple Ave.
Monrovia, CA 91016
(626) 256-1600

**G** មណ្ឌលសាធារណសុខភាព
**North Hollywood**
5300 Tujunga Ave.
N. Hollywood, CA 91601
(818) 766-3982
*បំរើតែកាមរោគ*

**H** មណ្ឌលសាធារណសុខភាព
**Pacoima**
13300 Van Nuys Blvd.
Pacoima, CA 91331
(818) 896-1903
*បំរើតែការចាក់ថ្នាំការពាររោគ និងរោគរបេង; វេជ្ជមន្ទីររោគរបេងគឺតាមការណាត់ជួប*

**I** មណ្ឌលសាធារណសុខភាព
**Pomona**
750 S. Park Ave.
Pomona, CA 91766
(909) 868-0235

**J** មណ្ឌលសាធារណសុខភាព
**Ruth Temple**
3834 S. Western Ave.
Los Angeles, CA 90062
(323) 730-3507
*បំរើតែកាមរោគ*

**K** មណ្ឌលសុខភាព និងសុខុមាលភាព **Simms/Mann**
2509 Pico Blvd.
Room 325
Santa Monica, CA 90405
(310) 998-3203
*បំរើតែកាមរោគ*

**L** មណ្ឌលសាធារណសុខភាព
**Martin Luther King, Jr.**
11833 S. Wilmington Ave.
Los Angeles, CA 90059
(323) 568-8100

**M** មណ្ឌលសាធារណសុខភាព
**Torrance**
711 Del Amo Blvd.
Torrance, CA 90502
(310) 354-2300

**N** មណ្ឌលសាធារណសុខភាព
**Whittier**
7643 S. Painter Ave.
Whittier, CA 90602
(562) 464-5350

## គំរោងការតំបន់សេវា

ខោនធី **Los Angeles** បានចែកទៅជាតំបន់ភូមិសាស្ត្រប្រាំបី ឬហៅថា គំរោងការតំបន់សេវា (**Service Planning Areas - SPA**)។ តំបន់ មណ្ឌលទាំងនេះ អនុញ្ញាតឲ្យក្រសួងសាធារណសុខភាព ផ្តល់ការថែទាំសុខភាពសាធារណៈ និងវេជ្ជមន្ទីរ ដែលស្របតាមសេចក្តីត្រូវការជាក់លាក់ នៅក្នុងតំបន់ទាំងនេះ។




### ការិយាល័យនាយកដ្ឋាន SPA

**Antelope Valley (SPA 1)**

**San Fernando Valley (SPA 2)**
បំរើសហគមន៍នៃ
Antelope, Santa Clarita, San Fernando និង Crescenta valleys
**(818) 487-0063**

**San Gabriel Valley (SPA 3)**

**Metro (SPA 4)**
បំរើសហគមន៍នៃ
Hollywood, Downtown Los Angeles, និង San Gabriel Valley
**(213) 240-8049**

**ខាងលិច (SPA 5)**

**ខាងត្បូង (SPA 6)**
បំរើសហគមន៍នៃ
South Central Los Angeles, West Los Angeles, និងតំបន់ Santa Monica Bay region
**(323) 730-3515**

**ខាងកើត (SPA 7)**

**South Bay (SPA 8)**
បំរើសហគមន៍នៃ
Gateway Cities, East Los Angeles, និង South Bay
**(562) 464-5478**

នាយកដ្ឋានសេវាសុខភាពសហគមន៍ : **(213) 240-8040**

## តើខ្ញុំអាចទាក់ទងអ្នកណា?

បញ្ជីនៃសេវា និងព័ត៌មានការទាក់ទងនៅខាងក្រោម សំរាប់កម្មវិធីមួយចំនួន ដែលក្រសួងសាធារណសុខភាពខោនធី **Los Angeles** បានផ្តល់ជូន។

**សំបុត្រកំណើត និងមរណភាព**
សំបុត្រកំណើត
(213) 240-7812
សំបុត្រមរណភាព
(213) 240-7816

**សេវាសុខភាពរបស់កុមារ**
សេវាកុមាររដ្ឋកាលីហ្វ័រនីញ៉ា (CCS) — ថែទាំសុខភាពសំរាប់ក្មេងៗដែលមានសេចក្តីត្រូវការថែទាំសុខភាពពិសេស
(800) 288-4584
កម្មវិធីការពារសុខភាពកុមារ និងភាពពិការ (CHDP) — ទទួលការពិនិត្យសុខភាពជាបង្ការ សំរាប់គ្រួសារមានប្រាក់ចំណូលតិច/មធ្យម និងក្មេងៗដែលមានការរ៉ាប់រង Medi-Cal
(800) 993-2437

**ការប្រុងប្រៀបសំរាប់អាសន្ន**
(213) 637-3600

**ជំងឺបណ្តាលពីការពុលអាហារ**
(213) 240-7821
(ថ្ងៃច័ន្ទ-សុក្រ, 8 ព្រឹក-5 ល្ងាច)
(213) 974-1234
(ពេលល្ងាច និងចុងអាទិត្យ)

**រោគ HIV/AIDS និងកាមរោគ**
(800) 367-AIDS (2437)
(ថ្ងៃច័ន្ទ-សុក្រ, 9 ព្រឹក-5 ល្ងាច; ភាសាអង់គ្លេស និងអេស្ប៉ាញ៉ុល)
(800) 758-0880
(ជាស្វ័យប្រវត្តិ 24 ម៉ោងមួយថ្ងៃ; ភាសាអង់គ្លេស និងអេស្ប៉ាញ៉ុល)
(213) 744-5949
(ថ្ងៃច័ន្ទ-សុក្រ, 9 ព្រឹក-5 ល្ងាច; មានអ្នកអប់រំសុខភាព)

**ការចាក់ថ្នាំការពាររោគ**
(213) 351-7800

**ការឲ្យគុណភាព និងការបិទភោជនីយដ្ឋាន**
(888) 700-9995

**ការរំលោភសារធាតុញៀន**
(626) 299-4193

**ពេទ្យសត្វត្រួតត្រាសាធារណសុខភាព និងជំងឺឆ្កែឆ្កួត**
(877) 747-2243

**សុខភាពរបស់ស្ត្រី**
(626) 569-3850
(ថ្ងៃច័ន្ទ-សុក្រ, 8 ព្រឹក-5 ល្ងាច)
(800) 793-8090
(លេខពិសេសសំរាប់ស្ត្រីមានប្រាក់ចំណូលតិច)

សំរាប់បញ្ជីល្អិតល្អន់ថែមទៀត និងព័ត៌មានទាក់ទងទាន់សភាពការណ៍បំផុត ឬដើម្បីរាយការណ៍ស្តីពីការយាយីដល់សុខភាពសាធារណៈ សូមមើលវ៉ិបសៃត៍របស់ក្រសួង នៅឯ **www.publichealth.lacounty.gov**។

**សំរាប់ព័ត៌មានបន្ថែម អំពីសុខភាពផ្សេងទៀត និងសេវាមនុស្សនៃខោនធី LA សូមហៅលេខ 2-1-1។**